# ធម៌ **អនត្តា**

ធម៌ អនត្តា នេះមានតែនៅក្នុងព្រះពុទ្ធសាសនា

យើងទេ ។ មានន័យថា ៖

*ខ្លួនយើង  មិនមែនជារបស់ យើង។*

*លោកអ្នក អាចសួរថា*

*បើខ្លួនយើង មិនមែនជារបស់យើង  តើវា ជារបស់*

*អ្នក ណា ?*

*លោកអ្នក នឹងរកឃើញ នូវចម្លើយនៃសំណួរនេះ  ដោយ ខ្លួនឯង បន្ទាប់ពីបានអាន អត្ថបទ ដូច តទៅនេះ .....។*

# ៨

## ធម៌អនត្តា

*ជាដំបូងខ្ញុំសូមធ្វើការវែកញែក រវាង ភាសាអ្នកស្រុក និង ភាសាធម៌ ។ ភាសាអ្នកស្រុក គឺជាភាសាដែលមនុស្សទូទៅបាន សន្មតប្រើ ដើម្បីប្រាស្រ័យទាក់ទងគ្នាក្នុងការរស់នៅក្នុងសង្គមមនុស្ស មិនថា ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬ អ្នកនៅក្រៅព្រះពុទ្ធសាសនាឡើយ។ ចំពោះ ភាសាធម៌ វិញ គឺ ភាសាដែលជាប់ទាក់ទងនឹងធម៌ព្រះពុទ្ធ ។  ដូចជា ភាសាអ្នកស្រុកថា « វានេះជាកូនរបស់ខ្ញុំ »  ដល់ភាសាធម៌វិញថា  « កូនរបស់ខ្ញុំឯណា បើខ្ញុំ មិនមែនជារបស់ខ្ញុំផង » ។ ការខុសគ្នានេះ ខ្ញុំសូមពន្យល់ដូចតទៅនេះ ។*

នៅសម័យមុនពុទ្ធសាសនា មានសាសនាដទៃខ្លះមានរួចមកហើយ ដូចជា ព្រហ្មញ្ញសាសនាជាដើម។ ដោយទ្រឹស្តីខ្លះក្នុងព្រះពុទ្ធសាសនា ខុសពីសាសនាដទៃ ហេតុនេះហើយបានជា មានពាក្យខ្លះសរសេរអក្សរដូចគ្នា តែមានន័យខុសគ្នា។ ដូចជាពាក្យថា « យើង ឬ ខ្ញុំ » ជាដើម ។ តាមលទ្ធិ ក្រៅពីព្រះពុទ្ធខ្លះ គេថា មនុស្ស យើងម្នាក់ៗ ដល់ស្លាប់ទៅមាន អាត្មន ឬ ព្រលឹង[1] អមតៈ ជាប់តាមជានិច្ច ជាអចិន្រ្តៃយ៍ ពីជាតិមួយទៅជាតិមួយ ដូច្នេះ ពាក្យថា

| « យើង ឬ ខ្ញុំ » គឺសំដៅ អាត្មន ឬ ព្រលឹង |
|---|

(ក១) ។

ចំពោះទ្រឹស្តីព្រះពុទ្ធសាសនាវិញ មនុស្សយើងម្នាក់ៗ មានតែ **កាយ** និង **ចិត្ត** ឬ **ខន្ធ៥** <u>ហើយក៏គ្មានអ្វី ក្រៅពីខន្ធ៥ នេះដែរ</u> ។ ខន្ធ៥ មាន « **រូប វេទនា សញ្ញា សង្ខារ** និង **វិញ្ញាណ** » ។

ដូច្នេះចំពោះ<u>ពាក្យអ្នកស្រុក</u> ថា **យើងម្នាក់ៗ មាន កាយ និងចិត្ត** នោះ ត្រូវនឹងធម៌ព្រះពុទ្ធហើយ ដោយគ្រាន់តែសន្មតថា [ កាយ គឺ រូប ] និង [ ចិត្ត គឺ វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ] ។ ហើយពាក្យថា

| « យើង ឬ ខ្ញុំ » គឺសំដៅ កាយ និង ចិត្ត |
|---|

(ក២) ។

<u>តទៅនេះ ខ្ញុំសន្មត យក និយមន័យ (ក២) មកប្រើ រហូត បើខ្ញុំមិនបានបញ្ជាក់ ។</u>

ដោយ ធម៌ព្រះពុទ្ធ ៖

**អនិច្ចំ ទុក្ខំ អនត្តា** និងធម៌

---

[1] សូមអាន [1] L'enseignement du Bouddha Walpola Rahula , page75 នៅក្នុង « **ផ្នែកសៀវភៅ និង ឯកសារពិគ្រោះ** »

**សព្វេ សង្ខារា អនិច្ចា**

**សព្វេ សង្ខារា ទុក្ខា**

និង **សព្វេ ធម្មា អនត្តា**

*យើងបាន ៖*

***ធ១-*** *សង្ខារធម៌ទាំងឡាយ មិនទៀង* (សព្វេ សង្ខារា អនិច្ចា)

***ធ២-*** *ធម៌ណា មិនទៀង ធម៌នោះជាទុក្ខ* (អនិច្ចំ ទុក្ខំ)

***ធ៣-*** *ធម៌ណា មិនទៀង ធម៌នោះ មិនមែនយើង មិនមែនខ្លួនយើង មិនមែនរបស់យើង*

(សព្វេ ធម្មា អនត្តា ) *ហើយជា ទុក្ខ ។*

- *ដោយ ខន្ធ៥ ជាសង្ខារធម៌*[2] *ដូច្នេះ ខន្ធ៥ មិនទៀង* (*ដោយ ធ១*) *ហើយ*

« *យើង ឬ ខ្ញុំ* » *ក៏ មិនទៀង* (*ដោយ ក២*) ។

- ***ដោយ ធម៌ណាមិនទៀង ធម៌នោះ*** **មិនមែនយើង មិនមែនខ្លួនយើង មិនមែនរបស់**

***យើង ហើយជា ទុក្ខ*** (*ដោយ ធ៣*) ។

*<u>សង្កេត</u>*

*១- យើងឃើញថា និយមន័យ* (*ក១*) *និង និយមន័យ* (*ក២*) *ខុសគ្នាស្រឡះ ។*

*នេះគួរឲ្យឆ្ងល់ដែរ មនុស្សនៅតែមនុស្សដដែល ម្ដេចក៏មាននិយមន័យពីរខុសគ្នា ?*

*ការឲ្យនិយមន័យពីរខុសគ្នា អំពីមនុស្សនេះ មិនមែនមកពីមនុស្សដូរទេ គឺមកពីទ្រឹស្ដីពីរខុសគ្នា ។ ទ្រឹស្ដីទី១ ខាងព្រហ្មញ្ញសាសនា គេថា មនុស្សមានព្រលឹងទៀងនៅដដែលមិនផ្លាស់ប្រែប្រួល ។ ចំពោះទ្រឹស្ដីទី២ ដោយធម៌* **អនិច្ចំ** *និង* **កើតរលត់***គ្រប់តែសង្ខារធម៌ទាំងអស់ ដូច្នេះមនុស្សដូរគ្រប់ពេលវេលា ។*

---

[2] *ធម៌កើតឡើង ដោយគ្រឿងផ្សំ គឺដោយយកធម៌ដទៃមកផ្សំជាមួយគ្នា ដូចជាសម្ល កកូរ បានមក ដោយយកគ្រឿងជាច្រើនមកផ្សំបញ្ចូលលាយជាមួយគ្នា ។*

២- ដោយន័យ មនុស្សជួរគ្រប់ពេលវេលា នេះហើយ បានជាមានធម៌ព្រះចែងថា ៖

- នេះ[3] មិនមែន របស់អញ [Ceci ne m’appartient pas,] (1)

- អញ មិនមែន នេះ [je ne suis pas ceci,] (2)

- នេះ មិនមែន ខ្លួនអញ ។ [ceci n’est pas mon égo.] (3)

តទៅនេះ ជាការបកស្រាយតាមខ្ញុំយល់ ចំពោះ (1) (2) (3) ៖

(1) ក្នុងន័យថា ដូចរូបកាយ យើង កាលណាវាឈឺ វាក៏ឈឺទៅ ទុកជាយើងមិនចង់ឲ្យវាឈឺក៏ដោយ ។ បានន័យថាយើងបង្គាប់វាមិនបានដូចចិត្តយើងទេ ។ ដូច្នេះ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនជារបស់យើងទេ ។

(2) ក្នុងន័យថា យើង ឬ ខ្ញុំ ឬ អញ មិនមែន រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ទេ ។ យើងអាចសួរថា ចុះបើ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែន យើង ឬ ខ្ញុំ ឬ អញ តើ យើង ឬ ខ្ញុំ ឬ អញ ជាអ្វីទៅ? ឆ្លើយថា គឺ**ទទេ** អត់មានអ្វីទាំងអស់ គឺគ្រាន់តែជាពាក្យ សន្មត ក្នុងការប្រាស្រ័យ ទាក់ទងគ្នាតែប៉ុណ្ណោះ ។

(3) ក្នុងន័យថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែន ខ្លួនយើង ឬ ខ្លួនខ្ញុំ ឬ ខ្លួនអញទេ ។ ដែលយើងថា « អញៗ » នោះ អត់មានអ្វីនៅក្នុងនោះទេ ដូចពពុះទឹកអញ្ចឹង។

រួមសេចក្តីទៅ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ គឺ ខន្ធ៥ នេះ គេអត់ស្គាល់យើងថាជាម្ចាស់របស់គេទេ ។ គឺយើងទេតើ ដែលឃើញគេចេះប្រាស្រ័យទាក់ទងគ្នា គឺថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ចេះសហការជាមួយគ្នា យើងក៏<u>**តាំងខ្លួន**</u>ជាម្ចាស់នៃគេទៅ ហើយស្រឡាញ់គេ ជាប់ចិត្តនឹងគេ ហើយដល់ខន្ធ៥គេមិនស្តាប់បង្គាប់ យើង

[3] ពាក្យថា « នេះ » នៅទីនេះសំដៅសង្ខារធម៌ទាំងអស់ ដូចជា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាដើម ទោះបី ជាសង្ខារធម៌ ពី អតីត បច្ចុប្បន្ន ឬ អនាគត ផ្ទាល់ខ្លួន ឬ អ្នកដទៃ ក៏ដោយ ។

ក៏តាំងកើតទុក្ខតែខ្លួនឯង ។ ចំណែក  រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ គេអត់ដឹងពុ រវីរវល់នឹងការឈឺចាប់យើងទេ ។ នេះជាការពិត ខំគិតនិងសង្កេតបន្តិចទៅ នឹងឃើញហើយ។ លោកអ្នកអាចសួរថា តើត្រូវធ្វើដូចម្តេច បើបានជាជ្រុលស្រឡាញ់គេទៅហើយ ? តើរកអ្នកណាជួយបានទេ ? ខ្ញុំឆ្លើយថាបាន បើសុខចិត្តពិចារណាតាមដែលខ្ញុំបានធ្លើរួចមកហើយ ។

ខ្ញុំថា **ពិចារណា** តាមខ្ញុំ ។ តែខ្ញុំមិនបានថា **ឲ្យធ្វើតាមខ្ញុំ** នោះទេ ។ ពីព្រោះខ្ញុំមិនមានបំណងបង្ខំលោកអ្នកឲ្យធ្វើតាមខ្ញុំទេ  តែបើបន្ទាប់ពីពិចារណាទៅ  លោកអ្នកយល់ដូចខ្ញុំដែរ នោះលោកអ្នកក៏ធ្វើតាមការយល់របស់លោកអ្នកទៅ ។  នេះហើយដែលហៅថាជឿ ឬ យល់ដោយប្រើបញ្ញា ។ បើថ្ងៃមុខស្រាប់តែឃើញខុសទៅវិញ កុំមកបន្ទោសខ្ញុំត្រូវបន្ទោសខ្លួនយើង កុំបន្ទោសអ្នកដែលប្រាប់យើង ។ ឥឡូវនេះខ្ញុំសូមជំរាបរបៀបដែលខ្ញុំបានពិចារណា។

ខ្ញុំគិតថា ឥឡូវនេះ បានជាជ្រុលតាំងខ្លួនជាម្ចាស់នៃ ខន្ធ៥  គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណនេះទៅហើយ  « អាត្មាអញ នៅតែតាំងតទៅទៀតចុះ » ។ ***តែត្រូវប្រយ័ត្ន មិនឲ្យចិត្ត[4] នេះ មកទាញអញឲ្យទៅរក សេចក្តីទុក្ខដែលអញមិនចង់ជួបនោះឡើយ*** ។ លោកអ្នកអាចសួរថា បើចិត្តមិនស្តាប់បង្គាប់យើងផង មិនមែនជារបស់យើងផង តើឲ្យយើងប្រយ័ត្ន  របៀបណា ? ដើម្បីនឹងឆ្លើយ សូមលោកអ្នកសង្កេតមើល ដើមឈើ វានៅក្រៅពីខ្លួនយើង ហើយមិនចេះស្តាប់ភាសាខ្មែរផង ម្តេចយើងពត់វាឲ្យត្រង់បាន  ហើយសត្វដំរី ខ្លាំងជាងយើងផង ម្តេចក៏ហ្មដំរី ប្រើវាឲ្យទាញឈើហ៊ុបបាន ? ចំពោះចិត្តយើងក៏ដូច្នោះដែរ  យើងអាចអប់រំចិត្តយើងបាន ។ យើងដឹងហើយថាចិត្តមានពីរពួកធំៗ

[4] តាមភាសាអ្នកស្រុក  ចិត្ត នៅទីនេះ គឺសំដៅយក វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ វិញ្ញាណខន្ធ  ហើយរូបរាងកាយ គឺ  រូបខន្ធ ។  ដូច្នេះ  មនុស្សយើងម្នាក់ៗ  តាមភាសាអ្នកស្រុក មាន កាយ និង ចិត្ត ។

គឺចិត្តកុសល និងចិត្តអកុសល ។ ចិត្តអកុសលនាំយើងទៅរក «ទុក្ខ» ហើយចិត្តកុសលនាំយើងទៅរកសេចក្តីសុខ ទាំងបច្ចុប្បន្ន ទាំងអនាគត ។ ដូច្នេះដើម្បីជៀសទុក្ខ ត្រូវអប់រំចិត្តឲ្យធ្វើតែអំពើជាកុសល និង កុំឲ្យធ្វើអំពើអកុសល ។ បើនិយាយតាមភាសាអ្នកស្រុក គឺយើងសន្សំបុណ្យឲ្យបានច្រើន ហើយកុំធ្វើបាប ។ ដូច្នេះ ចិត្ត ពិតមែនតែមិនមែនជារបស់យើងក៏ដោយ តែយើងអាចអប់រំវាបាន ដោយយើងប្រើ **ចិត្តកុសល** ឲ្យទៅវាយប្រហារ **ចិត្តអកុសល** ហើយតែកាលណាចិត្តកុសលវាយឈ្នះចិត្តអកុសលហើយ នោះយើងដែលមិនមែនជាម្ចាស់នៃចិត្តទាំងពីរ នឹងបានសុខហើយ ។

រួមសេចក្តីទៅ បើយើងសុខចិត្ត ថា យើង ហើយនិង ខន្ធ៥ គឺដូចតែគ្នា[5] សុខចិត្តរួមសុខទុក្ខជាមួយគ្នា គឺថា បើចិត្ត នៃខន្ធ៥ បានសុខ យើងក៏បានសុខដែរ បើចិត្តនៃខន្ធ៥ មានទុក្ខ យើងក៏មានទុក្ខដែរ ។ ដោយយើងសុទ្ធតែចង់បានសុខគ្រប់ៗគ្នា យើងខំអប់រំ ចិត្តនៃខន្ធ៥ នោះទៅ ពោលគឺយើងកុំធ្វើបាប ដែលជាប្រភពនៃទុក្ខ ។ ធ្វើរបៀបនេះ ត្រូវនឹងច្បាប់ធម្មជាតិ ហើយ ច្បាប់ធម្មជាតិនេះក៏ជាធម៌ព្រះពុទ្ធដែរ។ បន្ទាប់ពី បានអប់រំចិត្ត ដូចខ្ញុំបានជំរាបខាងលើនេះហើយ លោកអ្នកខំពិចារណាតទៅទៀត។ ពិចារណាលើអ្វីទៅ? គឺពិចារណាថា ខន្ធ៥នេះ ជាទុក្ខ នេះតាមធម៌ព្រះពុទ្ធ ។ ដោយធម៌ព្រះពុទ្ធ ជាធម្មជាតិ ដូច្នេះយើងសង្កេតមើលអ្នកនៅ ជុំវិញខ្លួនយើងតាំងពីប្រពន្ធកូនយើង រហូតដល់អ្នកដទៃ **តើខន្ធ៥ជាទុក្ខ ដូចពុទ្ធដីកាទេ?** នេះហើយការពិចារណា ដែលខ្ញុំបាននិយាយរហូតមកទល់ពេលនេះ ។ **គឺពិចារណានូវធម៌ព្រះពុទ្ធ ថាត្រូវ ឬ មិនត្រូវ ដោយពឹងផ្អែក ទៅលើការសង្កេតនូវអ្វីៗទាំងអស់ដែលនៅជុំវិញខ្លួនយើង ។**

[5] ដូចតែគ្នា ជៀតែក្អួច ឬ ក៏ថា « មួយដំប និង បួន » ។

*ធម៌មួយទៀតដែលគួរយកមក**ពិចារណាដែរ** គឺ ថា **តណ្ហា** ការស្រឡាញ់ ប្រកាន់ថា ខ្លួន (រូបខន្ធ)យើង ជារបស់យើង ជាហេតុមួយនាំឲ្យកើតទុក្ខដែរ កាលណាខ្លួនយើង ចាស់ ស្បែកជ្រីវជ្រួញ ធ្មេញបាក់ ជាដើម ។ នេះមកពីអ្វី? គឺមកពី ធម៌មិនទៀង ។ ឧបមាដូចយើងទៅពឹងលើបង្គោលមួយ ដោយស្មានថាបង្គោលនោះមាំ តែដល់ថ្ងៃ មួយបង្គោលនោះបាក់ទៅ យើងក៏លិចលង់ទៅជាមួយនឹងបង្គោលនោះដែរ យ៉ាង ណាមិញ ដោយនឹកថាខន្ធ៥ទៀង មិនចេះស្លាប់ ដល់ថ្ងៃណាមួយស្លាប់មកដល់ ក៏ទុក្ខសោក ជាមួយនឹងខន្ធ៥នោះទៅ ។ នេះមកពីយើង យល់ថា ខន្ធ៥ ថាទៀង ថាជារបស់យើង ។ ដូចមានគាថាទី៦២ ក្នុងធម្មបទ ដូចតទៅនេះ ៖*

**បុត្តាមត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**

**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។**

ជនពាល តែងក្តៅក្រហល់ក្រហាយថា បុត្រទាំងឡាយរបស់អញមាន ទ្រព្យសម្បត្តិរបស់ អញមាន តាមការពិត **<u>ខ្លួនមិនមែនជារបស់ខ្លួន</u>** បុត្រទាំងឡាយនឹងមានមកពីណា ទ្រព្យនឹងមានមកពីណា ។

*សំណួរមួយទៀត មុននឹងបញ្ចប់ តើយើងខឹងនឹងបង្គោលដែលបាក់ ព្រោះតែពឹង មិនបាន? ឬ មួយក៏អាណិតបង្គោលដែលបាក់នោះ ។ ខ្ញុំយល់ថា គួរតែអាណិតអាសូរ ដល់បង្គោលដែលបាក់នោះ ពីព្រោះគ្នាក៏នៅក្រោមច្បាប់ អនិច្ចំ ដែរ ។ ច្រកចេញ មានតែ ពួតដៃគ្នា[6]កម្ចាត់ចិត្តអកុសល ដើម្បីបានសុខ សម្រេចនិព្វាន ។*

[6] *គឺយើងពួតដៃជាមួយនឹង ខន្ធ៥ ។*